ក្រុមប្រឹក្សារដ្ឋមន្ត្រី

សាធារណរដ្ឋប្រជាមានិតកម្ពុជា

ឯករាជ្យ-សន្តិភាព-សេរីភាព-សុភមង្គល

លេខ : ១១ អ.ន.ក្រ

# អនុក្រឹត្យ

## ស្តីពីបទបញ្ជាផ្ទៃក្នុងរបស់កំពង់ផែសំរាប់នាវា បរទេសដែលចេញ-ចូលកំពង់ផែ នៃសាធារណរដ្ឋប្រជាមានិតកម្ពុជា

## ក្រុមប្រឹក្សារដ្ឋមន្ត្រី

- បានឃើញរដ្ឋធម្មនុញ្ញ នៃសាធារណរដ្ឋប្រជាមានិតកម្ពុជា
- បានឃើញច្បាប់ស្តីពីអង្គការចាត់តាំង និងសកម្មភាពរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ដែលប្រកាសអោយប្រើ ដោយក្រឹត្យលេខ ០៣ ចុះថ្ងៃ ទី ១០ ខែ កុម្ភៈ ឆ្នាំ ១៩៨២
- បានឃើញក្រឹត្យស្តីពីព្រំដែនសមុទ្រកម្ពុជាលេខ ០៨ ចុះថ្ងៃទី ៣១-៧-៨២

## សំរេច

### មាត្រា ១ :

នាវាបរទេសទាំងឡាយដែលចូល ឬ ចេញពីកំពង់ផែនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ត្រូវអនុវត្តតាមបទបញ្ជា ដែលមានចែងក្នុងមាត្រាជាបន្តបន្ទាប់ដូចខាងក្រោម ។

មាត្រា៤ៈ

ពីស្ថានីយ៍កណ្តូធារ ឬ ពីចំណុចពោងស្ទ្រូមកកំពង់ផែ ហាមដាច់ខាតមិនអោយប្រើវិទ្យុបញ្ជូនសម្លេង មិនអោយ ថតខ្សែភាពយន្ត ថតរូប ឬ ទាក់ទងជាមួយនាវា ឬ ទូកផ្សេង ៗ ទៀត ឬ ជាមួយប្រជាជន។

មាត្រា៥ៈ

មុនពេលធ្វើការត្រួតពិនិត្យ និង ក្នុងពេលកំពុងធ្វើការត្រួតពិនិត្យនាវាចូល ឬ ក្រោយពេលធ្វើការត្រួតពិនិត្យ និង ក្នុងពេលកំពុងធ្វើការត្រួតពិនិត្យនាវាចេញ ហាមមិនអោយនាវិក ឬ អ្នកដំណើរចេញពីនាវា និង ទាក់ទងជាមួយជនផ្សេងទៀត ក្រៅពីគណៈកម្មការត្រួតពិនិត្យ ភ្នាក់ងារនាវាចរណ៍កណ្តូធារ ភ្នាក់ងារការិយាល័យនាវាចរណ៍ និង កិច្ចការកំពង់ផែ និង ភ្នាក់ងារសន្តិសុខព្រំដែនឡើយ។

ក្នុងករណីដែលមានមនុស្សមិនស្របច្បាប់នៅលើនាវា មេបញ្ជាការនាវាត្រូវរាយការណ៍ទៅគណៈកម្មការត្រួតពិនិត្យ ។

មាត្រា ៦ៈ

នាវិកនឹងអ្នកដំណើរទាំងអស់ ត្រូវមានវត្តមាននៅពេលធ្វើការត្រួតពិនិត្យ ។ មេបញ្ជាការនាវា ឬ តំណាងមេបញ្ជាការនាវាដែលមានភារកិច្ចប្រចាំថ្ងៃ ត្រូវបានអនុញ្ញាតិអោយចូលរួមក្នុងរយៈពេលធ្វើការត្រួតពិនិត្យបែបបទ ។

ក - មេបញ្ជាការនាវា ឬ តំណាងមេបញ្ជាការនាវាត្រូវប្រគល់ឯកសារដូចខាងក្រោមនេះទៅអោយគណៈកម្មការត្រួតពិនិត្យ ៖

៥ - ប្រតិវេទន៍វិញ្ញាបនប័ត្រពន្យាពេល

៦ - លិខិតបញ្ជាក់របស់ចំតាឡើងក ចំពោះនាវិកនិងអ្នកដំណើរ

៧ - លិខិតបញ្ជាក់បានសម្លាប់សត្វកណ្ដុរលើនាវាអស់ហើយ

៨ - សៀវភៅនាវិកនិងលិខិតឆ្លងដែនអ្នកដំណើរ

៩ - ប័ណ្ណទំនិញឆ្លងដែនមានទំនិញធម្មតា រុក្ខជាតិ និងសត្វមានជីវិត ។

នាវាត្រូវអនុញ្ញាតិ អោយចូលផែក្រោយពីគណៈកម្មការបានធ្វើការត្រួតពិនិត្យរួចហើយ ។

## មាត្រា ៧ :

នាវាដែលចូលចតនៅកំពង់ផែ ត្រូវលើកទង់ជាតិរបស់សាធារណរដ្ឋប្រជាមានិតកម្ពុជា ចាប់ពីម៉ោង ៦ ព្រឹក ដល់ម៉ោង ១៨ ជារៀងរាល់ថ្ងៃ ។

ក្នុងរយៈពេលស្ថិតនៅក្នុងរង្វង់កំពង់ផែ នាវាត្រូវលើកទង់អក្សរពេលបុណ្យជាតិរបស់សាធារណរដ្ឋប្រជាមានិតកម្ពុជា និងបុណ្យអន្តរជាតិកាលណាការិយាល័យនាវាចរណ៍ និងកិច្ចការកំពង់ផែបានផ្ដល់ពត៌មានអោយ ។

បើចង់លើកទង់អក្សរពេលបុណ្យជាតិរបស់ខ្លួន នាវាត្រូវសុំការអនុញ្ញាតិពីការិយាល័យនាវាចរណ៍និងកិច្ចការកំពង់ផែ ។

## មាត្រា ៨ :

ក្នុងពេលស្នាក់នៅកំពង់ផែ នាវាត្រូវអនុវត្តតាមបញ្ជារបស់ប្រធានការិយាល័យនាវាចរណ៍ និងកិច្ចការកំពង់ផែ ដូចជាការផ្លាស់ប្ដូរទីកន្លែង ការបោះយុថ្កា ការចងព្រួរ ។

មាត្រា១២ :

ប្រសិនបើនាវាបានធ្វើ អោយកើតហេតុអ្វីមួយ បណ្តាលអោយខូចដល់សំភារៈ របស់កំពង់ផែ ក៏ដូចជាបណ្តាសំណង់ផ្សេងៗ និង ទ្រព្យសម្បត្តិប្រជាជន មេបញ្ជាការនាវាត្រូវតែរាយការណ៍ជាបន្ទាន់អោយការិយាល័យនាវាចរណ៍ និង កិច្ចការកំពង់ផែជ្រាប និងត្រូវតែទទួលខុសត្រូវទាំងស្រុងចំពោះបង្គ័យអាក្រក់ ព្រមទាំងការបង់ខាតទាំងឡាយ ។

មាត្រា១៣ :

ក្នុងពេលចតនៅកំពង់ផែ នាវាត្រូវអនុវត្តវិធានការអនាម័យដូចតទៅ :

មិនបង្ហូរទឹកស្អុយ បង្ហូរកាកប្រេង ផុកបំពង់ផ្សែង ចោលសំរាមនិងកាកសំណល់ផ្សេង ៗ ទៀត ក្នុងផ្ទៃទឹករបស់កំពង់ផែ ឬ នៅលើផែ ។ បើត្រូវការចាក់ចោលសំរាម ឬ ដោះស្រាយការចាំបាច់ដូចពោលខាងលើ នាវាត្រូវធ្វើលិខិតសំណូមពរទៅការិយាល័យនាវាចរណ៍ និង កិច្ចការកំពង់ផែ ដែលមានភារកិច្ចដោះស្រាយជូន តែនាវាត្រូវទូទាត់ចំណាយ ។

ពេលចតនៅកំពង់ផែ ត្រូវអនុវត្តកម្មវិធីចាក់សំរាមទាំងនោះប្រាំថ្ងៃម្តង ហើយត្រូវបង្កលក្ខណ ងាយស្រួលអោយកម្មករយកសំរាមនោះអោយបានល្អស្អាត និងចុះហត្ថលេខានៅលើកំណត់ហេតុក្រោយពីបានបញ្ចប់ការងារ ។

ខ្សែពួរទាំងឡាយដែលចងនាវាភ្ជាប់នឹងផែ ត្រូវមានឧបករណ៍ការពារ « កុំអោយកណ្តុរ ឆ្លងតាមខ្សែពួរទាំងនោះ » ។

២ - លាក់បំពួន ឬ ប្រើមធ្យោបាយផ្សេង ៗ ដែលជាហេតុនាំអោយប៉ះពាល់ដល់សណ្តាប់ធ្នាប់ និងសន្តិសុខនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា

៣ - លាក់មនុស្សមិនស្របច្បាប់លើនាវា ឬ ដាក់មនុស្សចុះក្នុងមកដីកំពង់ផែដោយគ្មានការអនុញ្ញាត ។

៤ - មានការទាក់ទងនិងធ្វើជំនួញជាមួយប្រជាជន នៅក្នុងបរិវេណកំពង់ផែ

៥ - ដាក់ទូកតូច ក្បូន ឬ សំភារៈផ្សេង ៗ ក្នុងទឹកលើកលែងតែកិច្ចការនោះបានអនុញ្ញាត ពីការិយាល័យនាវាចរណ៍ និងកិច្ចការកំពង់ផែ ។

៦ - ថតរូប គូររូប វាស់ស្ទង់កន្លែងផ្សេង ៗ ដែលបានហាមឃាត់ ។

៧ - មានសកម្មភាពប្រឆាំងនឹងសាធារណរដ្ឋប្រជាមានិតកម្ពុជា ។

៨ - ចាប់ ឬ ស្ទូចត្រី មុជទឹក ឬ ហែលទឹកក្នុងបរិវេណកំពង់ផែ ។

*មាត្រា ១៨ :*

នាវិក ឬ អ្នកដំណើរ ដែលបានអនុញ្ញាតិអោយឡើងគោក ឬ ឡើងទៅលើនាវាផ្សេង ៗ ឬ ត្រូវបានអញ្ជើញដោយភ្នាក់ងារសន្តិសុខព្រំដែនត្រូវ :

១ - បង្ហាញលិខិតអនុញ្ញាត ឬ លិខិតឆ្លងដែនក្នុងពេលត្រូវការ ។

២ - គោរពបទបញ្ញត្តិកំពង់ផែ បទបញ្ញត្តិក្រុង និងច្បាប់សាធារណរដ្ឋប្រជាមានិតកម្ពុជា អ្នកទាំងនោះមិនត្រូវធ្វើសកម្មភាពនាំអោយរំខានដល់សន្តិសុខសង្គម និងរបៀបរៀបរយសាធារណៈ ។ ភាពស្រវឹង អាវ៉ាសែត្រូវបានហាមឃាត់ដាច់ខាត ។

មាត្រា ២២ :

នាវាទាំងអស់ដែលចូលមកសាធារណរដ្ឋប្រជាមានិតកម្ពុជា ត្រូវអនុវត្តតាមច្បាប់អន្តរជាតិផ្នែកសុខាភិបាល ។ មន្ទីរចត្តាឡីស័កកម្ពុជា ត្រូវពិនិត្យជាប្រក្រតីនូវស្ថានភាពសុខភាពរបស់មនុស្សនៅក្នុងនាវាក្នុងរង្វង់កំពង់ផែ ។ បេបញ្ហាការនាវាត្រូវអនុវត្តតាមការណែនាំរបស់ក្រុមចត្តាឡីស័កកម្ពុជា ។

មាត្រា ២៣ :

នាវាដែលដឹកនាំសត្វមកជាមួយ ត្រូវរាយការណ៍ និង អនុវត្តតាមច្បាប់បសុពេទ្យនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ។

សត្វនៅក្នុងនាវាត្រូវមានវិញ្ញាបនប័ត្របសុពេទ្យ ។ សត្វទាំងនោះអាចដាក់ចុះពីនាវាបានលុះត្រាតែបានពិនិត្យរួច និង មានការអនុវត្តពីបសុពេទ្យកម្ពុជា ហើយមិនត្រូវអោយរត់ ឬ ដើរពាសពេញផែឡើយ ។

មាត្រា ២៤ :

ទំនិញដែលផលិតចេញពីសត្វ ត្រូវមានវិញ្ញាបនប័ត្របសុពេទ្យ និង វិញ្ញាបនប័ត្រសំខាន់ផ្សេង ៗ ទៀត ហើយត្រូវបង្ហាញទៅគណៈកម្មការត្រួតពិនិត្យ ។ ទំនិញប្រភេទនេះអាចយកចេញបាន លុះត្រាតែមន្ទីរបសុពេទ្យបានពិនិត្យរួចហើយអនុញ្ញាត ។

មាត្រា ២៥ :

កាលណាបានចូលក្នុងដែនទឹកនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា នាវាដែលមានផ្ទុកទំនិញធញ្ញជាតិត្រូវបិទឃ្លុបអោយជិត ដើម្បីបង្ការសត្វល្អិត សត្វចង្រៃចង្រៃដែលអាចនាំមកជាមួយចូលក្នុងទឹកដីកម្ពុជា ។

*មាត្រា ២៨ :*

ការប្រព្រឹត្តល្មើសនឹងអនុក្រឹត្យនេះ នារាបរទេសត្រូវទទួលពិន័យតាមច្បាប់របស់សាធារណរដ្ឋប្រជាមានិតកម្ពុជា ។

*មាត្រា ២៩ :*

រដ្ឋមន្ត្រីគ្រប់ក្រសួង និងគណៈកម្មាធិការប្រជាជនបដិវត្តរដ្ឋធានី និងក្រុងកំពង់សោមត្រូវទទួលបន្ទុកអនុវត្តអនុក្រិត្យនេះតាមភារកិច្ចរៀងៗខ្លួន ។

ភ្នំពេញ, ថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ១៩៨៣

ជ ក្រុមប្រឹក្សារដ្ឋមន្ត្រី

ប្រធាន

ហត្ថលេខានិងត្រា

ចាន់-ស៊ី

ចម្លងជូន :

- ខុទ្ទកាល័យមជ្ឈឹមបក្ស
- ខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋ

« ដើម្បីជ្រាបជាពតិមាន »

- គ្រប់ក្រសួងជុំវិញមជ្ឈឹម
- គណៈកម្មាធិការប្រជាជនបដិវត្តរដ្ឋធានីភ្នំពេញនិងក្រុងកំពង់សោម

« ដើម្បីអនុវត្ត »

គ្រប់គណៈកម្មាធិការប្រជាជនបដិវត្តខេត្តទាំងអស់

« ដើម្បីជ្រាបជាពតិមាន »

- ឯកសារ

លេខ ១៩ ច.ល

បានចម្លងជូនត្រឹមត្រូវតាមច្បាប់ដើម

ភ្នំពេញ, ថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ១៩៨៣

រដ្ឋមន្ត្រីទទួលបន្ទុកខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋមន្ត្រី

អ៊ុំ-ផន